ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៣៨/០៨ - ម៉ាលីន ហ្គាមិន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **លី តៃសេង**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

១-ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ម៉ាលីន ហ្គាមិន**

អាសយដ្ឋាន : ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៥៩៨ ៧៤៨ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក : **អវត្តមាន**

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សហព័ន្ធសហជីព_សហជីពឃុំទជនខ្មែរ នៃក្រុមហ៊ុន ម៉ាលីន ហ្គាមិន**

អាសយដ្ឋាន : ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ :០១២ ៣១០ ៣២០ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត : **អវត្តមាន**



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

## បញ្ហាក្ដីវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត មានលក្ខណៈងាយស្រួល ។

២- កម្មករនិយោជិតទាមទារនៅពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ សុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលពេញ និងទូទាត់សងឡើងវិញជូនកម្មករនិយោជិត ។

៣- ចំពោះកម្មករនិយោជិតដែលធ្វើកិច្ចសន្យាការងារមានថិរវេលា ហើយដល់កាលកំណត់នៃកិច្ចសន្យា សុំឱ្យក្រុមហ៊ុនគិតទូទាត់ប្រាក់ ៥ ភាគរយ ជូនកម្មករនិយោជិត និងបូកទាំងអត្ថប្រយោជន៍ផ្សេងៗ ។

៤- នៅពេលកម្មករនិយោជិត ដែលធ្វើការបន្ថែមម៉ោង នៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យសុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ថ្លៃបាយចំនួន ២០០០ រៀល ។

៥- ចំពោះកម្មការិនី ដែលដាក់ច្បាប់ឈប់សម្រាកលំហែមាតុភាព ៩០ ថ្ងៃ (សម្រាលកូន) សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ៥០ ភាគរយ និងប្រាក់បន្ទាប់បន្សំមុនថ្ងៃដាក់ច្បាប់ឈប់សម្រាក ។

៦- នៅពេលដែលធ្វើការបន្ថែមម៉ោងសុំឱ្យក្រុមហ៊ុនអនុវត្តលើគោលការណ៍ស្ម័គ្រចិត្តរបស់កម្មករនិយោជិត ។

៧- នៅពេលដែលកម្មករនិយោជិតមានជំងឺ ហើយបានសម្រាកព្យាបាលនៅមន្ទីរពេទ្យត្រឹមត្រូវ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់នៅដដែល ។

៨- ចំពោះកម្មករនិយោជិត ដែលចូលជាសមាជិកសហជីពយុវជនខ្មែរ សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលក្នុងម្នាក់ៗចំនួន ១០០០ រៀល ដើម្បីបង់ភាគទានជូនសហជីពយុវជនខ្មែរ ជារៀងរាល់ខែ ។

៩- កម្មករនិយោជិតទាមទារសុំក្រុមហ៊ុនបើកប្រាក់ថ្លៃបាយក្នុងមួយសប្ដាហ៍ម្ដងវិញ ។

១០- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនដកសន្តិសុខឈ្មោះ ពិសី ចេញពីក្រុមហ៊ុន ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១១៩៧ ក.ប/អក/វ.ក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ វេលាម៉ោង ១៤:០០ នាទី (ភាគីសហជីព និង កម្មករនិយោជិត និងភាគីនិយោជក អវត្តមាន)។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់កម្មករនិយោជិត ស្តីពីការទាមទារឱ្យក្រុមហ៊ុន ម៉ាលីន ហ្គាមិន កែលំអរនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួម ចំនួន ១០ ចំណុច និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីសហជីព កម្មករនិយោជិត ប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០នាទី ប៉ុន្តែភាគីសហជីព កម្មករនិយោជិត មិនបានមកចូលរួមសវនាការ ហើយក៏មិនបានបញ្ជាក់ពីមូលហេតុ ឬស្នើសុំពន្យាពេលសវនាការ ដោយបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយឡើយ។ ចំណែកឯភាគីនិយោជកវិញ ក៏មិនបានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ទោះបីជាលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្យាយាមទាក់ទងយ៉ាងក៏ដោយ ក៏មិនអាចទាក់ទងបានដែរ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះដូចខាងក្រោម :

## អង្គហេតុ

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក-ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

18

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉ាលីន ហ្គាមិន លេខ ១១៩៧ កប/អក/វក. ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមក្រុមហ៊ុន ម៉ាលីន ហ្គាមិន ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦៨៥ កប/អក/លកអ. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦៨៤ កប/អក/លកអ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨។

**អង្គហេតុ**

- **គ្មាន**

**ហេតុផលនៃសេចក្តីសម្រេច**

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាដើមបណ្តឹង មិនបានចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមិនបានបញ្ជាក់ពីមូលហេតុ ដែលមិនមកចូលរួមសវនាការទេ ទោះបីជាពួកគេទទួលបានលិខិតអញ្ជើញត្រឹមត្រូវ និងតាមរយៈទូរស័ព្ទរំលឹកឱ្យចូលរួមសវនាការ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃសវនាការ ក៏ដោយ ។ ចំណែកឯភាគីនិយោជកវិញ ក៏មិនបានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរទោះ បីជាលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្យាយាមទាក់ទងយ៉ាងណាក៏ដោយ ក៏មិនអាចទាក់ទងបានដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោមៈ

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "* ។

ប្រការ ២១ នៃ ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា *" ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្ត*

*ដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់"។*

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសគី លេខ ២៧/០៧-អ៊ីម និង វ៉េ ៣ លេខ ៧៣/០៧-សាន់ ស៊ីន និង លេខ ១៣២/០៨-ជី អេច ជី ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយប្រការ ២១ នៃ ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ខាងលើនេះថា ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបិទសំណុំរឿងមួយបាន មានលក្ខខណ្ឌបីដែលត្រូវបំពេញគឺ *"លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹង ដោយត្រឹមត្រូវ, លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"។*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏យល់ស្របនឹងការបកស្រាយប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ របស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងត្រឹមត្រូវ**

ដោយផ្អែកលើចំណុច (ឃ) ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីនៃវិវាទពិតជាទទួលបានលិខិតអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

នៅក្នុងសំណុំរឿងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ **"ពាក្យបង្ហាញខ្លួនក្នុងសវនាការ" ដែលមានចែងក្នុង**ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ និង

ឃ-ដំណាក់កាលសវនាការដល់អង្គសេចក្តី។

ក្នុងករណីនេះ ភាគីសហជីព កម្មករនិយោជិត ក៏ដូចជាភាគីនិយោជក មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព កម្មករនិយោជិត និងភាគីនិយោជក មិនបានបង្ហាញខ្លួននៅក្នុងសវនាការតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ខាងលើនេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី ២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព កម្មករនិយោជិត និងភាគីនិយោជក មិនបានផ្តល់ហេតុផលណាមួយ សម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះមកដល់ថ្ងៃសវនាការ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០ នាទី លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទាក់ទងតាមទូរស័ព្ទរំលឹកភាគីនិយោជក និងសហជីពកម្មករនិយោជិត ស្រាប់តែភាគីសហជីពកម្មករនិយោជិតបានឆ្លើយថា ពួកគេមិនអាចអញ្ជើញចូលរួមសវនាការបានទេ ហើយក៏មិនបញ្ជាក់មូលហេតុដែរ។ មន្ត្រីលេខាធិការដ្ឋានបានសួរបញ្ជាក់បន្ថែមទៀតថា តើអាចឱ្យតំណាងកម្មករនិយោជិត ឬ ថ្នាក់ដឹកនាំសហជីពណាម្នាក់មកចូលរួមសវនាការបានទេ។ ភាគីសហជីព កម្មករនិយោជិតបានបញ្ជាក់ថា ពួកគេមិនអាចមកចូលរួមសវនាការនេះបានឡើយ ហើយទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចតាមនីតិវិធីចុះ។ ចំណែកឯភាគីក្រុមហ៊ុន ក៏មិនបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់ដែរ បើទោះជាលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាលព្យាយាមទាក់ទងយ៉ាងក៏ដោយ ក៏មិនអាចទាក់ទងបានដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី ៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើត្រូវបានបំពេញ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបី ភាគីនៃវិវាទមិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សហជីព កម្មករនិយោជិតនៃរោងចក្រ ម៉ាលីន ប្អាមិន ដែលជាភាគីដើមបណ្តឹងក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ សហជីព កម្មករនិយោជិតបានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណី ភាគីដើមបណ្តឹងមិនចូលរួមក្នុង

THE ARBITRATION COUNCIL

សវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្ដល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា នេះជាការបោះបង់បណ្ដឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈដោយសុទ្ធចិត្តរបស់ភាគីសហជីព កម្មករនិយោជិត ក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបិទសំណុំរឿងលេខ ១៣៨/០៨-ម៉ាលីន ហ្គាមិន នេះ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផល ដូចបានការពន្យល់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

- សម្រេចបិទសំណុំរឿងលេខ ១៣៨/០៨-ម៉ាលីន ហ្គាមិន

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **លី តៃសេង**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ----------------------------------------

THE ARBITRATION COUNCIL